# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jan-2016, 13:50
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**សំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឲ្យទទួលយកឯកសារមួយ មកធ្វើជាភ័ស្តុតាងសម្រាប់ការសួរដេញដោលសាក្សី 2-TCW-938**

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

លោក Clément BOSSIS

កញ្ញា Cécile ROUBEIX

កញ្ញា អ៊ួច ស្រីផាត

កញ្ញា Marine BOUDJEMAA

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្ដី លោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានសម្រេចឯកភាពតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យស្តាប់ចម្លើយសាក្សី 2-TCW-938[1]។ មេធាវីការពារក្តីលោក ខៀវ សំផន (“មេធាវីការពារក្តី”) បានជំទាស់ទៅនឹងសំណើមួយនេះ ដែលផ្អែកលើភ័ស្តុតាងមួយចំនួនយកមកពីសំណុំរឿង ០០៣ និង ០០៤[2]។

២. នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា សាក្សី 2-TCW-938 អាចនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦[3]។

៣. នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បង្ហាញឯកសារចំនួនប្រាំចេញពីសំណុំរឿង ០០៤ ដែលឯកសារទាំងប្រាំនោះ ពាក់ព័ន្ធនឹងការប្រព្រឹត្តលើជនជាតិចាម[4] ដោយសហព្រះរាជអាជ្ញាបានបញ្ជាក់ថា ឯកសារនីមួយៗ “*មានផ្ទុកទៅដោយភ័ស្តុតាងដោះបន្ទុកសំខាន់ៗ*” និង/ឬ “*អាចស្នើសុំ អនុលោមតាមវិធាន ៨៧(៤)*”[5]។

---

[1] សេចក្តីសម្រេចទៅលើឯកសារ E368, E366 និងសំណើមេធាវីការពារក្តី ខៀវ សំផន សុំពន្យារពេលស្តាប់សក្ខីកម្មអ្នកជំនាញ 2-TCE-95 (ឯកសារ E366/1) ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **E372,** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យកោះហៅសាក្សីបន្ថែម ក្នុងអំឡុងពេលសវនាការនៃសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិចាម ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E366/3** (ផ្អែកសំអាងហេតុ)។

[2] ចម្លើយរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំស្តាប់សក្ខីកម្មរបស់សាក្សីបីរូបថែមទៀត ពាក់ព័ន្ធនឹងការប្រព្រឹត្តលើជនជាតិចាម និងសំណើបន្ទាប់បន្សំសុំបញ្ជីឈ្មោះសាក្សីសរុបដែលត្រូវមកបង្ហាញខ្លួននៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E366/1**។

[3] អ៊ីមែលលោក ROBERTS ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ មានចំណងជើងថា៖ “ការកំណត់កាលបរិច្ឆេទសវនាការបន្ថែមទៀត៖ ការប្រព្រឹត្តលើក្រុមមនុស្សគោលដៅ”។

[4] ការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារមួយចំនួនពីសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២ អនុលោមតាមសំណុំរឿង ០០៤-D193/61 ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E319/39** (ការដាក់បង្ហាញនេះត្រូវបានជូនដំណឹងជាការគួរសម មុនមួយថ្ងៃ)។

[5] ឧបសម្ព័ន្ធ **E319/39.2** ឬ **E319/39.3**។

៤. ក្នុងថ្ងៃដដែលនោះដែរ អង្គជំនុំជម្រះបានសម្រេចផ្លាស់ប្ដូរលំដាប់លំដោយសាក្សីដែលត្រូវមកផ្ដល់សក្ខីកម្ម។ ហេតុដូច្នេះ សាក្សី 2-TCW-938 អាចនឹងត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦[6]។

៥. តាមរយៈសារណានេះ មេធាវីការពារក្ដី ស្នើសុំឱ្យទទួលយកឯកសារមួយ ក្នុងចំណោមឯកសារទាំងប្រាំដែលត្រូវបានដាក់បង្ហាញកាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ មកធ្វើជាភ័ស្ដុតាងអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[7] ដើម្បីមេធាវីការពារក្ដីអាចប្រើប្រាស់ឯកសារនេះបាន ក្នុងពេលសួរដេញដោលសាក្សី 2-TCW-938។

៦. ឯកសារ E319/39.3.1 ជាកំណត់ហេតុស្ដាប់ចម្លើយសាក្សីមួយរូបដែលមានតួនាទីនៅក្នុងតំបន់ជាមួយគ្នាដែរ ដែលចម្លើយរបស់គាត់អាចយកមកជំទាស់ជាអាទិ៍ទៅនឹងការលើកឡើងរបស់សាក្សី 2-TCW-938 ពាក់ព័ន្ធការសន្មតដែលថា ប្ដីរបស់គាត់មានអំណាចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[8] ។ ដូច្នេះ វាពិតជាមានសារៈសំខាន់ដែលអាចតទល់សាក្សី 2-TCW-938 ទៅនឹងចម្លើយទាំងអស់នេះ។

៧. ដូច្នេះ ការទទួលយកឯកសារ E319/39.3.1 ដែលទើបតែអាចរកបានប៉ុន្មានថ្ងៃមកនេះ មកធ្វើជាភ័ស្ដុតាង ពិតជាមានសារៈសំខាន់ក្នុងការស្វែងរកការពិត និងសម្រាប់ផលប្រយោជន៍យុត្តិធម៌។

៨. <u>**ផ្អែកតាមសំអាងហេតុនេះ**</u> មេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះ មេត្តាទទួលយកឯកសារ E319/39.3.1 ធ្វើជាភ័ស្ដុតាង មុននឹងមេធាវីការពារក្ដីសួរដេញដោលសាក្សី 2-TCW-938។

---

[6] ប្រតិចារឹកសវនាការថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ សេចក្ដីព្រាងប្រតិចារឹក ទំព័រ ៤២ និង ៤៣ មុនម៉ោង [១៣.៣៧.៣៣]។

[7] "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្ដួចផ្ដើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្ដាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភ័ស្ដុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្ដីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣) ខាងលើ ។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភ័ស្ដុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្ដើមជំនុំជម្រះ"។

[8] ឧទាហរណ៍ សូមមើល ឯកសារ **E319/39.3.1** ចម្លើយទី ១៨, ឯកសារ **E3/9310** ERN KH 00963133, FR 01157197, EN 01064277។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>រាជធានីភ្នំពេញ | |